# ការបញ្ជាបឱ្យយល់ច្បាស់ពីសេចក្តីសម្រេចលើកទីពីររបស់អង្គបុរេជំនុំជម្រះលើការបណ្តឹងឧទ្ធរណ៍អំពីបទចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយ

*ដោយសាស្ត្រាចារ្យ ដេវិត សេហ្វហ្វឺ*

*ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ចៅក្រមទាំងប្រាំរូបរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មិនបានសម្រេចបោះឆ្នោតគាំទ្រជាមតិច្រើន (ក្នុងចំណោមចៅក្រមបួនរូប) ក្នុងបញ្ហារុករកកំហុសដែលអាចកើតមាននៅក្នុងសេចក្តីសម្រេចកាលពីមុន របស់សហចៅក្រមស៊ើបអង្កេត ដែលមិនយល់ស្របធ្វើការសន្និដ្ឋានថា ការជ្រៀតជ្រែកផ្នែកនយោបាយដែលបានកើតមានឡើងនៅក្នុងអង្គបុរេជំនុំជម្រះទេ ។ នេះគឺជាគោលបំណងរបស់ នួន ជា និង អៀង សារី ក្នុងការកោះហៅសាក្សីដែលជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ឲ្យចូលធ្វើសក្ខីកម្ម ។ ជនជាប់ចោទទាំងពីរនាក់ខាងលើនេះរំពឹងថានឹងស្វែងរកឃើញនូវភស្តុតាងដែលធ្វើឲ្យខ្លួនរួចទោសសម្រាប់រឿងក្តី០០២ របស់ខ្លួនដែលអាចនឹងចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០១១ ។ ចៅក្រមជាតិបីរូបរបស់អង្គបុរេជំនុំជម្រះបានច្រានចោលបណ្តឹងឧទ្ធរណ៍ដែលជនជាប់ចោទទាំងពីររូបបានធ្វើឡើង ។ នេះមានន័យថា ក្នុងអំឡុងពេលនេះ គោលបំណងកោះហៅសាក្សីទាំងប្រាំមួយរូបនេះត្រូវបានផ្អាកមួយរយៈសិន ហើយការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយពីសំណាក់រដ្ឋាភិបាលកម្ពុជាលើកិច្ចការរបស់ អ.វ.ត.ក ដែលកើតឡើងជាបន្តបន្ទាប់យូរមកហើយនេះ នឹងមិនត្រូវបានស៊ើបអង្កេតជាបន្តទៀតដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះឡើយ ។

ចៅក្រមអន្តរជាតិពីររូបរបស់អង្គបុរេជំនុំជម្រះបានចេញសេចក្តីមិនយល់ស្របដោយជំទាស់ថា “នៅក្នុងការស្វាបស្ទង់ភស្តុតាងដែលគាំទ្រការចោទប្រកាន់ពីការជ្រៀតជ្រែក ដែលអាចកើតមានឡើងនៅក្នុងការគ្រប់គ្រងលើវិស័យយុត្តិធម៌ ទស្សនៈរបស់យើងគឺថារាល់ភស្តុតាងដែលសមហេតុផលណាមួយត្រូវបានពិចារណាឃើញថា ភស្តុតាងសំខាន់ៗ និងឯកសារជាប់ពាក់ព័ន្ធរបស់ភស្តុតាងនោះបានផ្តល់ជាមូលហេតុមួយក្នុងការជឿថាសមាជិកម្នាក់ ឬក៏ច្រើននាក់របស់រាជរដ្ឋាភិបាលកម្ពុជាប្រហែលជាមានជាប់ពាក់ព័ន្ធនឹងសាក្សីដែលអាចផ្តល់ភស្តុតាងនៅចំពោះសហចៅក្រមស៊ើបអង្កេតដោយចេតនានិងដោយដឹងជាមុន ។

ការបញ្ចេញមតិរបស់លោក ខៀវ កាញារីទ្ធិ អ្នកនាំពាក្យរដ្ឋាភិបាលដែលថ្លែងថា “គោលជំហររបស់រដ្ឋាភិបាល គឺថាមន្ត្រីរដ្ឋាភិបាលទាំងប្រាំមួយរូបនេះមិនគួរធ្វើសក្ខីកម្មទេ” នេះធ្វើឲ្យយើងពេញចិត្តត្រង់ថា ការធ្វើបែបនេះគឺជាហេតុផលមួយក្នុងការជឿថាមន្ត្រីរូបនោះ ឬក៏ជនណាផ្សេងទៀត ដែលនិយាយជំនួសមន្ត្រីនោះមានបំណងគំរាមកំហែង ឬគាបសង្កត់មន្ត្រីទាំងប្រាំមួយរូបនោះ ឬបើមិនដូច្នោះទេ ជ្រៀតជ្រែកក្នុងសេចក្តីសម្រេចចិត្តរបស់មន្ត្រីទាំងប្រាំមួយរូប ទាក់ទិនពីការអញ្ជើញចូលខ្លួនធ្វើបទសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ” ។

វាពិតជាមិនល្អប្រសិនបើលទ្ធផលដែលអង្គបុរេជំនុំជម្រះសម្រេចបានបណ្តាលឲ្យមានមតិរិះគន់ អ.វ.ត.ក ថាជាវិទ្យាស្ថានច្បាប់មួយដែលមានលក្ខណៈមិនគ្រប់គ្រាន់ ដែលការបង្រួបបង្រួមគ្នារវាងអង្គបុរេជំនុំជម្រះ និង អ.វ.ត.ក នេះ ត្រូវបានប្រឈមមុខនឹងការជ្រៀតជ្រែកផ្នែកនយោបាយ ។ សេចក្តីសម្រេចថ្ងៃទី៩ ខែកញ្ញា មិនមែនកើតចេញពីវិធានបោះឆ្នោតជាមតិភាគច្រើននៃច្បាប់ អ.វ.ត.ក ឡើយ ហើយវាក៏មិនបណ្តាលមកពីទស្សនៈឯកច្ឆន្ទស្តីពីការចោទប្រកាន់ ការជ្រៀតជ្រែកផ្នែកនយោបាយដោយចៅក្រមអន្តរជាតិដែលជាប់ពាក់ព័ន្ធទាំងអស់ដែរ ។ ខ្ញុំពិតជាគាំទ្រការមិនយល់ស្របរួមរបស់ចៅក្រមអន្តរជាតិ ខាតថារីន ម៉ារឆី យូហែល និង រ៉ូវ៉ាន ដោនីង ដែលថាលទ្ធផលរបស់បញ្ហានេះកើតចេញពីសេចក្តីវិនិច្ឆ័យចុងក្រោយបង្អស់របស់សហចៅក្រមស៊ើបអង្កេត ម៉ារសែល ឡឺម៉ង់ និង សេចក្តីសន្និដ្ឋានសមហេតុផលដែលសម្រេចដោយចៅក្រមជាតិរបស់អង្គបុរេជំនុំជម្រះពីលក្ខណៈ និង ផលប៉ះពាល់នៃសេចក្តីថ្លែងការរបស់ ខៀវ កាញារីទ្ធ នៅក្នុងទំព័រកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ។

ការច្រានចោលបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ មិនមានអ្វីពាក់ព័ន្ធនឹងវិធានបោះឆ្នោតជាមតិភាគច្រើននោះទេ ។ ចៅក្រមបីរូបក្នុងចំណោមប្រាំរូប (មតិភាគច្រើនសាមញ្ញ) បានសម្រេចច្រានចោលបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ។ សម្រាប់អ្នកដែលគាំទ្របទដ្ឋានបោះឆ្នោតជាមតិភាគច្រើននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់តុលាការ ជាជាងបទដ្ឋានបោះឆ្នោតជាមតិភាគច្រើន ដែលមានស្រាប់របស់ អ.វ.ត.ក អ្នកទាំងអស់នោះត្រូវតែទទួលស្គាល់ថា អង្គបុរេជំនុំជម្រះបានគោរពតាមបទដ្ឋានបោះឆ្នោតជាមតិភាគច្រើន (ជាមួយនឹងសម្លេងបីលើសពីរក្នុងការចេញសេចក្តីច្រានចោលនេះ) ។ មិនមានទស្សនៈគាំទ្រជាមតិភាគច្រើនក្នុងការគាំទ្របណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីររូបនេះទេ ។ បញ្ហាពិតប្រាកដនោះគឺថាតើរចនាសម្ព័ន្ធដើមរបស់ អ.វ.ត.ក ក្នុងការសម្រេចឲ្យមានចៅក្រម

ជាតិច្រើនជាងចៅក្រមអន្តរជាតិនៅក្នុងអង្គជំនុំជម្រះនីមួយៗ រួមទាំងអង្គបុរេជំនុំជម្រះ គឺជាការរៀបចំត្រឹមត្រូវសម្រាប់ អ.វ.ត.ក ដែរឬទេ។ នោះគឺជាបញ្ហាចរចាយ៉ាងយូរវាងរដ្ឋាភិបាលកម្ពុជា និងចៅក្រមអង្គការសហប្រជាជាតិក្នុងទសវត្សរ៍ឆ្នាំ៩០ ប៉ុន្តែនៅក្នុងឆ្នាំ២០០០បញ្ហានេះត្រូវបានព្រមព្រៀងថានឹងមានចៅក្រមជាតិច្រើនជាងចៅក្រមអន្តរជាតិនៅក្នុងអង្គជំនុំជម្រះទាំងអស់របស់ អ.វ.ត.ក ប៉ុន្តែរាល់បញ្ហាទាំងអស់ត្រូវតែសម្រេចដោយវិធានបោះឆ្នោតជាមតិភាគច្រើន។ បើមិនធ្វើដូច្នោះទេ ក៏មិនមាន អ.វ.ត.ក ដូចសព្វថ្ងៃនេះដែរ។

ម្តងទៀត បើទោះបីជា អ.វ.ត.ក ត្រូវបានតាក់តែងឡើងដើម្បីបង្កើតជាវិធានបោះឆ្នោតដែលទាមទារឲ្យមានសេចក្តីសម្រេចចិត្តជាមតិគាំទ្រភាគច្រើននោះក្តី ក៏លទ្ធផលដូចគ្នានេះនៅតែកើតចេញពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី៩ ខែកញ្ញា ដដែល។ មធ្យោបាយដើម្បីចៀសវាងលទ្ធផលនៃថ្ងៃទី៩ ខែកញ្ញា គឺមានពីរ : ក. ចៅក្រមជាតិពីររូបត្រូវធ្វើការសហការជាមួយនឹងចៅក្រមអន្តរជាតិពីររូប ឬ ខ. ការតាក់តែងរចនាសម្ព័ន្ធរបស់អង្គបុរេជំនុំជម្រះថ្មីតម្រូវឲ្យមានចៅក្រមអន្តរជាតិច្រើនជាងចៅក្រមជាតិ ដែលនេះគឺជាការកើតមានឡើងនូវវិធានបោះឆ្នោតជាមតិភាគច្រើន។ ប្រសិនបើអនុវត្តដូច្នេះ យើងអាចសន្និដ្ឋានបានថា ចៅក្រមអន្តរជាតិទាំងអស់នឹងគាំទ្រទស្សនៈរបស់ចៅក្រមម៉ាឆី យូហែល និង ដោនីង ចំពោះបញ្ហាទាក់ទិននឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយបោះឆ្នោតគាំទ្របណ្តឹងឧទ្ធរណ៍នេះជាមិនខាន។ ប៉ុន្តែជម្រើសចុងក្រោយខាងលើនេះគឺជាបញ្ហាផ្នែករចនាសម្ព័ន្ធដែលយើងអាចគ្រាន់តែគិតពីលទ្ធភាព«ចុះប្រសិនបើ»តែប៉ុណ្ណោះ មិនមែនជាបញ្ហាដែលពាក់ព័ន្ធនឹងសមាសធាតុរចនាសម្ព័ន្ធរបស់អង្គបុរេជំនុំជម្រះនិងវិធានបោះឆ្នោតជាមតិភាគច្រើនបច្ចុប្បន្ននេះទេ។

ការពិតមួយទៀត នៅសេចក្តីសម្រេចច្រានចោលបណ្តឹងឧទ្ធរណ៍នេះ គឺថាចៅក្រមជាតិទាំងបីរូបបានពឹងផ្អែកយ៉ាងខ្លាំងលើមូលហេតុដែលថាទាំងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិបានយល់ព្រមបដិសេធសំណូមពររបស់ជនជាប់ចោទទាំងពីរខាងលើឲ្យសហចៅក្រមធ្វើការស៊ើបអង្កេត នៅក្នុងកំឡុងពេលដំណើរពិនិត្យឡើងវិញលើកទីពីររបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ហើយចៅក្រមជាតិទាំងនោះមិនបានរកឃើញនូវការជ្រៀតជ្រែកផ្នែកនយោបាយ ដែលតម្រូវឲ្យមានជាវិធានការណ៍ត្រួតពិនិត្យតាមវិធានផ្ទៃក្នុង៣៥(១)របស់តុលាការឡើយ។ ដូច្នេះ នេះគឺដោយសារតែចៅក្រមអន្តរជាតិដែលដំបូងឡើយគាំទ្រការនាំយកសាក្សីមកធ្វើសក្ខីកម្មនៅចំពោះមុខតុលាការ បានសហការជាមួយនឹងដៃគូចៅក្រមជាតិរបស់ខ្លួន នៅក្នុងការពិនិត្យរើកញែកចុងក្រោយ ដោយសម្រេចបដិសេធមិនធ្វើការស៊ើប

អង្កេត ។ នេះគឺជាសេចក្តីសម្រេចរួម ដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះមួយចំនួនបានធ្វើការរិះគន់យ៉ាងខ្លាំង ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើសេចក្តីសម្រេចជាលើកចុងក្រោយមួយ ដែលយល់ស្របនឹងចៅក្រមស៊ើបអង្កេតជាតិ ។ ចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះធ្វើការរិះគន់លើ«ការបរាជ័យជាបន្តបន្ទាប់ រួមទាំងការចាត់វិធានការណ៍របស់សហចៅក្រមស៊ើបអង្កេត» ដែលតែងតែចាំបាច់ត្រូវការការអន្តរាគមន៍ពីសំណាក់អង្គបុរេជំនុំជម្រះ ។

ចៅក្រមជាតិបីរូបរបស់អង្គបុរេជំនុំជម្រះ ធ្វើការកត់សម្គាល់នៅក្នុងមតិផ្សេងៗគ្នារបស់ខ្លួន កាលពីថ្ងៃទី៩ ខែកញ្ញា ថ្មីៗនេះថា នៅពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសឆ្គងនៅក្នុងការបកស្រាយវិធានផ្ទៃក្នុង៣៥ ហើយបានប្រព្រឹត្តនូវកំហុសច្បាប់មួយ ។ ជាមួយគ្នានេះ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេត «ធ្វើការពិចារណាឡើងវិញថា តើគួរតែធ្វើការស៊ើបអង្កេតដើម្បីទាញយកទស្សនៈផ្ទាល់របស់ជនដែលត្រូវកោះហៅ និងជនដទៃទៀតដែលបម្រើឲ្យរាជរដ្ឋាភិបាលកម្ពុជា ដែលអាចនឹងជះឥទ្ធិពលលើសមត្ថភាពនិងការស្ម័គ្រចិត្តរបស់សាក្សីទាំងអស់នោះ ដែលត្រូវបានកោះហៅដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យចូលរួមធ្វើបទសម្ភាសន៍» ។ ចៅក្រមជាតិរបស់អង្គបុរេជំនុំជម្រះបានពឹងផ្អែកយ៉ាងខ្លាំងលើការពិនិត្យឡើងវិញលើកទីពីរ លើសេចក្តីសម្រេចមិនធ្វើការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ ហើយចៅក្រមជាតិទាំងបីរូបរបស់អង្គបុរេជំនុំជម្រះ បានចេញសេចក្តីជំទាស់សមហេតុផលថា ការពិនិត្យឡើងវិញបន្ថែមទៀតលើភស្តុតាងខ្លះៗ បានធ្វើឲ្យចៅក្រមជាតិទាំងនោះជឿលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការមិនធ្វើការស៊ើបអង្កេត ។

ការផ្អែកយ៉ាងចម្បងរបស់ចៅក្រមអង្គបុរេជំនុំជម្រះលើហេតុផលរបស់សហចៅក្រមស៊ើបអង្កេត ដែលក្នុងចំណោមនោះក៏មានចៅក្រមអន្តរជាតិម្នាក់ដែរនោះ អាចនឹងមានឥទ្ធិពលផ្សេងគ្នា ប្រសិនបើសហចៅក្រមអន្តរជាតិនោះគាំទ្រឲ្យមានការស៊ើបអង្កេតបន្ថែមទៀតនៅក្នុងការពិនិត្យឡើងវិញលើកទីពីរ លើសេចក្តីសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេត ។ ដូច្នេះចៅក្រមរបស់អង្គបុរេជំនុំជម្រះអាចនឹងបង្គាប់ឲ្យមានការស៊ើបអង្កេត ។ ក្នុងលទ្ធភាពបែបនេះ ច្បាស់ជាមានការបង្គាប់បញ្ជាឲ្យធ្វើការស៊ើបអង្កេតលើបទចោទប្រកាន់ពីការជ្រៀតជ្រែកពីរដ្ឋាភិបាលជាមិនខាន ហើយការមិនយល់ស្របគ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិអាចនឹងត្រូវបានតម្រូវឲ្យមានវិធានការណ៍បោះឆ្នោតជាមតិភាគច្រើនប្រសិនបើអង្គបុរេជំនុំជម្រះត្រូវបានជម្រុញឲ្យដោះស្រាយស្ថានភាពទ័លច្រកនេះ ។ ដូច្នេះ

ចៅក្រមជាតិរបស់អង្គបុរេជំនុំជម្រះ  មិនអាចផ្លាស់ប្តូរសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យបន្តធ្វើការស៊ើបអង្កេតបានឡើយ  ប្រសិនបើចៅក្រមអន្តរជាតិទាំងពីររូបរបស់អង្គបុរេជំនុំជម្រះមានទស្សនៈយ៉ាងមុតមាំដែលចៅក្រមទាំងនោះបានបង្ហាញកាលពីថ្ងៃទី៩ ខែកញ្ញា កន្លងទៅនេះ ។ (សូមអានវិធានផ្ទៃក្នុង៧២(៤)(ឃ)) ។ ប៉ុន្តែ ហេតុការណ៍ទាំងអស់ខាងលើនេះ មិនមែនជាការពិតដែលត្រូវបានទទួលដឹងឮនោះទេ ។

ប្រាកដណាស់ ទស្សនៈមិនយល់ស្របរបស់ចៅក្រមអន្តរជាតិពីររូបរបស់អង្គបុរេជំនុំជម្រះគឺជាសញ្ញាណដ៏ល្អមួយដែលថា  សេចក្តីជំទាស់ដ៏មានឥទ្ធិពលដែលស្នើដោយចៅក្រមនោះកំពុងតែត្រូវបានឆ្លុះបង្ហាញឲ្យឃើញយ៉ាងច្បាស់លាស់  បើទោះបីជាសេចក្តីជំទាស់បែបនេះមិនមានឥទ្ធិពលនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះក៏ដោយ ។  វាអាចទៅរួចដែលថាអង្គជំនុំជម្រះសាលាដំបូង  ឬក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រាប់រឿងក្តី០០២អាចមានឱកាសមួយប្រឈមមុខនឹងបញ្ហានេះ  ហើយអាចនឹងជឿជាក់លើទស្សនៈមិនយល់ស្របរបស់ចៅក្រមអន្តរជាតិបាន ។

ប្រសិនបើគ្មានការយល់ដឹងពីកស្តុតាងទាំងអស់ជុំវិញបញ្ហានេះទេនោះ  វាពិតជាពិបាកក្នុងការអះអាងថាតើរចនាសម្ព័ន្ធរបស់តុលាការបានប្រឈមមុខនឹងសម្ពាធផ្នែកនយោបាយដែរឬយ៉ាងណា ។ ដូច្នេះហើយបានជាវាមានការទាមទារឲ្យមានការស៊ើបអង្កេតដោយ នួន ជា និង អៀង សារី ហើយនិងចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះ ។  គ្មាននរណាម្នាក់ដឹងច្បាស់ថាតើសាក្សីដ៏ចាំបាច់ទាំងនោះបានទទួលឥទ្ធិពលពីសេចក្តីថ្លែងការរបស់ ខៀវ កាញារីទ្ធិ ដែលសាក្សីទាំងនោះបានបដិសេធមិនបង្ហាញខ្លួននោះឬយ៉ាងណានោះទេ ។ ប៉ុន្តែ សេចក្តីសម្រេចលើកទីមួយដោយសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកដោយមតិភាគច្រើនរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះនោះបានអនុម័តថាមិនបន្តពិភាក្សាពីបញ្ហានេះទៀតឡើយ ។  ចៅក្រមទាំងអស់បានផ្តល់ជាការបកស្រាយដ៏សមហេតុផលលើ  សេចក្តីថ្លែងការរបស់ ខៀវ  កាញារីទ្ធិ ។  ខ្ញុំនឹងមិនសន្និដ្ឋានថានេះគឺជាកំហុសដ៏ធ្ងន់ធ្ងរមួយដែលកើតមាននៅក្នុងរចនាសម្ព័ន្ធរបស់តុលាការនោះទេ ប៉ុន្តែវាអាចចាត់ទុកថាជាសេចក្តីសម្រេចខុសមួយ ។

ជាការកត់សម្គាត់មួយផ្សេងទៀត  ខ្ញុំសូមបន្ថែមទៀតថា  នៅសហរដ្ឋអាមេរិក  យើងពិតជាភ្ញាក់ផ្អើលលើសេចក្តីសម្រេចជាមតិភាគច្រើនរបស់ចៅក្រមមួយចំនួនតូចនៅក្នុងរឿងក្តីរដ្ឋ និងសហព័ន្ធ ។ ហើយយើងឆ្ងល់ថាតើចៅក្រមទាំងនោះអាចនឹងចេញសេចក្តីសម្រេចដែលគ្មានហេតុផល  និងយុត្តិធម៌បែបនេះ

ដោយរបៀបណា ។ យើងស្ងប់ស្ងែងនឹងការត្រិះរិះរបស់ចៅក្រមប្រឆាំងដែលទស្សនៈរបស់ចៅក្រមទាំង នោះអាចគួរឲ្យជឿបាននៅចំពោះមុខតុលាការខុទ្ទរណ៍ ឬតុលាការកំពូលរបស់សហរដ្ឋអាមេរិក ។ ប៉ុន្តែ យើងនឹងមិនសួរដេញដោលពីរចនាសម្ព័ន្ធរបស់យើងនោះទេ បើទោះបីជាចៅក្រមតែងតាំងមួយចំនួន អាចនឹងទទួលឥទ្ធិពលពីមនុស្សមួយចំនួនដែលគាំទ្រការតែងតាំងរបស់ខ្លួនក៏ដោយ ។

សេចក្តីសម្រេចលើកទីពីរកាលពីថ្ងៃទី៩ ខែកញ្ញា របស់អង្គបុរេជំនុំជម្រះ គឺពិតជាមានសារសំខាន់ ណាស់ ហើយនឹងតម្រូវឲ្យមានការត្រួតពិនិត្យបន្ថែមនាពេលប៉ុន្មានខែខាងមុខនេះ ។ មួយរយៈកន្លងទៅ នេះ អ.វ.ត.ក បានបំពេញតួនាទីតាមអំណាចរបស់ខ្លួន ហើយបានចេញសេចក្តីសម្រេច និងការជំទាស់ សមហេតុផលជាច្រើនទាក់ទិននឹងបញ្ហានេះ ។ តាមទស្សនៈរបស់ខ្ញុំគឺថា ជំពូកចុងក្រោយស្តីពីបញ្ហានេះ នៅមិនទាន់បានសរសេរនៅឡើយទេ ។